ថ្ងៃ ចន្ទ ទី ១៩ ខែ មិថុនា ឆ្នាំ២០២៣

អនុវិទ្យាល័យ ហ៊ុនសែនរលួស ថ្នាក់ទី៖ 7"A" ឈ្មោះ៖ ជិត សុសាតា ភេទ៖ ស្រី អាយុ៖ 13 ឆ្នាំ	ពិន្ទុ	មូលវិចារ

មិត្តស្មោះត្រង់

ខ្ញុំមានមិត្តសាលាច្រើន តែក្នុងចំណោមមិត្តទាំងអស់នោះ មានម្នាក់ដែលល្អនិងស្មោះត្រង់ជាងគេ។ មិត្តម្នាក់នោះមានឈ្មោះថា ជិន ធាវីតា។ នាងមានអាយុ១២ឆ្នាំ។ សព្វថ្ងៃនាងរស់នៅក្នុងភូមិឈាយជ័យ ឃុំត្រពាំងធំ ស្រុកប្រាសាទបាគង ខេត្តសៀមរាប។

មិត្តរបស់ខ្ញុំម្នាក់នេះពិតជាល្អខ្លាំងណាស់។ នាងមានចរិតស្លូតបូត សុភាពរាបសារ ស្មោះត្រង់ចេះគោរពចាស់ទុំ និងមានទន់ភ្លន់ស្រីយល្អ ដល់មិត្ត។ មិនតែប៉ុណ្ណោះ ធាវីតាជាមិត្តល្អ និងជាអ្នកទំនុកចិត្ត។ មិនត្រឹមតែប៉ុណ្ណោះ នាងថែមនាងមានចិត្តសន្ដោស ស្មោះសរ បរិសុទ្ធ ឥតលាក់លៀម និងឥតពុត។ ម្យ៉ាងវិញទៀត នាងតែងតែស្ដាប់បង្គាប់ឪពុកម្ដាយ និងលោកគ្រូអ្នកគ្រូ។ លើសពីនេះទៀត នាងតែងតែលើកស្ទួយមិត្តដែលប្រព្រឹត្តអំពើល្អ ត្រឹមត្រូវ។ ក្រៅពីនេះទៀត ធាវីតា នាងតែងតែពន្យល់ណែនាំមិត្តណាដែលប្រព្រឹត្តអំពើដែលខុសឆ្គង ឱ្យមានចរិតល្អ ត្រឹមត្រូវតាមការបង្ហាត់បង្រៀនរបស់ឪពុកម្ដាយ និងលោកគ្រូអ្នកគ្រូ។ លើសពីនេះទៀត គ្រប់កាលៈទេសៈ ធាវីតា នាងតែងតែជួយទុក្ខធុរៈ ជួយឧបត្ថម្ភគ្នាទៅវិញទៅមក ឱ្យមានសេចក្ដីក្សេមក្សាន្តជាមិត្ត។ មិនតែប៉ុណ្ណោះ ធាវីតាមិនដែលបោះបង់ពេលគ្នាក្នុងគ្រាមានអាសន្នមួយណាឡើយ។ ពេលទំនេរ ធាវីតាតែងតែបបួលមិត្តភក្ដិក្នុងថ្នាក់ទៅក្នុងបណ្ណាល័យ ដើម្បីអានសៀវភៅ និងធ្វើលំហាត់ជាក្រុម។ មិនត្រឹមតែប៉ុណ្ណោះទេ នាងពិតជាឧស្សាហ៍ព្យាយាមសិក្សារៀនសូត្រ និងតែងតែជួយធ្វើកិច្ចការផ្ទះឪពុកម្ដាយ។ មិនត្រឹមតែប៉ុណ្ណោះទៀត នាងតែងតែយល់ពីចិត្តរបស់ខ្ញុំ ទុក្ខសុខ ទុក្ខ

ទុក្ខ ជួយទំនុកបម្រុងគ្នា និងណែនាំមិត្ត ឱ្យប្រព្រឹត្ត
តែអំពើជាកុសល ។
នៅថ្ងៃមួយ ខ្ញុំកើតជំងឺធ្លាក់ទឹកចិត្តដោយសារបញ្ហា
គ្រួសារ និងបញ្ហាក្នុងការសិក្សារៀនសូត្រ ដោយខ្ញុំងាក
ផ្ទឹក នាងតែងតែមកនិយាយលួងលោមលើកទឹកចិត្ត
ខ្ញុំ និងជួយឧបត្ថម្ភសម្ភារៈសិក្សាដល់ខ្ញុំខ្លះ ។ ក្រៅពីខ្ញុំគិតថានា
ងជាមិត្តល្អ អ្នកចេះជួយនិងររក ដំរែ ក៏គិតដូចខ្ញុំដែរ
ព្រោះនាងតែចេះជួយយកអាសារ ដាស់តឿន ក្រើនរំលឹក
មិត្តពេលធ្វើខុសឆ្គាំឆ្គង ជួយតម្រង់មេរៀនដែលពួកគេ
មិត្តយល់ មិនច្បាស់ ពេលមានបញ្ហាដល់មិត្ត និងចេះនិយាយលួង
លោមលើកទឹកចិត្ត មិត្តទៀតផង ។

ខ្ញុំពិតជាមានមោទនភាព ខ្លាំងណាស់ដែលបាន
ជានាង ជាមិត្ត ។ នៅថ្ងៃនេះក៏ដូចថ្ងៃអនាគត ខ្ញុំនិងស
ន្យាថា ខ្ញុំនិងស្រឡាញ់រាប់អាននាង ដូចបងប្អូនបង្កើតដែរ និង
រក្សាចំណងមិត្តភាពនេះ ឱ្យបានគង់វង្សយូរអង្វែង ឱ្យបានស្និទ្ធ
ស្នាលជារៀងរហូតទៅ ។

Special Note

- Good hand writing, meaningful, ~~used~~ good connected phrases or words, there are no any wrong spelling words and not too short and too long, clear and straight content to the topic...

Mark provided

- Grammar = 20
- Creativity = 27
- Content = 30
- W.C = 20

Total = 97